**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ៤១ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការផ្លាស់ប្តូរ និងបំពេញបន្ថែមសមាជិក សមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន ខេត្តរតនគិរី និងខេត្តស្វាយរៀងដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.-**

ត្រូវបានផ្លាស់ប្តូរពីសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តរតនគិរី** មកជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តស្វាយរៀង** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានសមាសភាពខាងក្រោម៖

១.**ឯកឧត្តម គាំ រឹបូន** អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិអេស្កាប់

២.**ឯកឧត្តម ស៊ុយ ជីហ៊ាង** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន

៣.**ឯកឧត្តម ទេព កល្យាណ** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន

៤.**ឯកឧត្តម ចៅ ជីអាន** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន។

**ប្រការ២** .-

ត្រូវបានបំពេញបន្ថែមសមាជិក សមាជិកាក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តស្វាយរៀង** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ដូចមានសមាសភាពខាងក្រោម៖

| | | |
|---|---|---|
| ១.**ឯកឧត្តម ព្រំ សុភមង្គល** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ២.**ឯកឧត្តម ឈីវ លីម** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ៣.**លោកជំទាវ ស្រេង សោភា** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិកា |
| ៤.**ឯកឧត្តម គី ប៊ុណ្ណាវុត** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិអេស្កាប់ | សមាជិក |
| ៥.**ឯកឧត្តម នូ កែវសុទ្ធា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិអេស្កាប់ | សមាជិក |
| ៦.**ឯកឧត្តម គឹម វាភ៉ា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិអេស្កាប់ | សមាជិក |
| ៧.**ឯកឧត្តម អ៊ឹង ស៊ានលី** | ទីប្រឹក្សាគណៈកម្មាធិការជាតិអេស្កាប់ | សមាជិក |
| ៨.**ឯកឧត្តម ភឹម រុនស៊ីណារិទ្ធិ** | ទីប្រឹក្សាគណៈកម្មាធិការជាតិអេស្កាប់ | សមាជិក |
| ៩.**ឯកឧត្តម ព្រំ សេរីឧត្តម** | ទីប្រឹក្សាអាជ្ញាធរមីន | សមាជិក |
| ១០.**ឯកឧត្តម ភ្លឹង ស៊ីនិត** | ទីប្រឹក្សាអាជ្ញាធរមីន | សមាជិក |
| ១១.**ឯកឧត្តម ចៅ ឡាយ** | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ១២.**ឯកឧត្តម គន់ សាភ៉ា** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច-សង្គមនិងគ្រប់គ្រងទិន្នន័យ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ១៣.**ឯកឧត្តម ជឹម ច័ន្ទស៊ីដេត** | ប្រធាននាយកដ្ឋានបទបញ្ញត្តិ និងត្រួតពិនិត្យ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ១៤.**ឯកឧត្តម អេង ភាព** | ប្រធាននាយកដ្ឋានទំនាក់ទំនងសាធារណៈ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក |
| ១៥.**ឯកឧត្តម មៅ ប៊ុនញាត** | ប្រធាននាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរមីន | សមាជិក។ |

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋានអាជ្ញាធរមីន គណៈកម្មាធិការជាតិអេស្កាប់ រដ្ឋបាលខេត្តរតនគិរី រដ្ឋបាលខេត្តស្វាយរៀង និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ស្ងៅក៍ ៣ រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២០

**អប.នាយករដ្ឋមន្ត្រី**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ